# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2019, 11:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សំណើរបស់លោក ខៀវ សំផន សុំធ្វើអោយភាពសេចក្ដីសម្រេច E463/1/3 លើបណ្ដឹងសាទុក្ខផ្សេងៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Marine BOUDJEMAA

កញ្ញា Dounia HATTABI

កញ្ញា ស៊ូស៊ែន ច័ន្ទចរិយា

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោស លោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថានឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្រប"[2]។

២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ហើយបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឲ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ ("បណ្តឹងសាទុក្ខ")[3]។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល[4] សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខតែជាភាសាអង់គ្លេសប៉ុណ្ណោះ[5]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ គឺមួយថ្ងៃក្រោយការជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញាជាភាសាខ្មែរ[6] មេធាវីការពារក្តីបានឆ្លើយតបទៅវិញ[7]។

---

[1] ប្រតិចារឹកសវនាការ ("ប្រតិចារឹក") ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣៨-៤២ ចន្លោះពីម៉ោង ១១:២៨ ដល់ម៉ោង ១១: ៣៨។

[2] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣ ប្រហែលម៉ោង ៩:៣៦។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** ("បណ្តឹងសាទុក្ខ") ជូនដំណឹងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបតែមួយភាសា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/1/1** ("សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា")។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1/2** ជូនដំណឹងនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨។ មេធាវីការពារក្តីបានស្នើសុំការបកប្រែចម្លើយតបនេះជាភាសាបារាំង ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨។

[6] អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតប ជាភាសាខ្មែរ យ៉ាងយូរបំផុត ត្រឹមថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ (សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ១០) ហើយ

៣. នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានជ្រើសតាំងចៅក្រមបម្រុង Phillip RAPOZA ឱ្យជំនួសចៅក្រម Agnieszka KLONOWIECKA-MILART សម្រាប់កិច្ចដំណើរការនីតិវិធី ("ដីកាជ្រើសតាំងចៅក្រមបម្រុង")[8]។ នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចបដិសេធបណ្តឹងសាទុក្ខ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ")[9]។

៤. តាមរយៈសារណានេះ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យធ្វើមោឃភាពសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ពីព្រោះសេចក្តីសម្រេចនេះបានចេញ ដោយរំលោភលើវិធានជាធរមាន (ផ្នែកទី ១) និងរំលោភលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់ (ផ្នែកទី ២)។

## ផ្នែកទី ១. ភាពមិនត្រឹមត្រូវនៃសមាសភាពក្រុមប្រឹក្សាចៅក្រម

៥. កាលប្បវត្តិនីតិវិធីបង្ហាញថា ក្នុងពេលធ្វើ និងចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ក្រុមប្រឹក្សាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលមិនមានសមាសភាព ស្របតាមវិធានជាធរមាននោះទេ។

---

សហព្រះរាជអាជ្ញាបានដាក់ចម្លើយតប នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨។ ចម្លើយតបជាភាសាខ្មែរនេះត្រូវបានជូនដំណឹង ១៥ ថ្ងៃក្រោយមក គឺនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។

[7] ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** ("ការឆ្លើយតប") ជូនដំណឹងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨។

[8] ដីកាជ្រើសតាំងចៅក្រមបម្រុង ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **F38**។ សំណៅច្បាប់ដើមជាភាសាអង់គ្លេសនៃដីកានេះមានចំណងជើងថា *« Order Appointing Reserve Judge »* និងចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ("ដីកាជ្រើសតាំងចៅក្រមបម្រុង")។ មេធាវីការពារក្តីបានជូនដំណឹងដល់អង្គភាពបកប្រែភាសា និងប្រតិចារិក អំពីកំហុសទាំងនេះ និងកំហុសផ្សេងទៀតក្នុងសំណៅបកប្រែជាភាសាបារាំង ប៉ុន្តែ កំហុសទាំងនេះនៅតែមិនទាន់ត្រូវបានកែតម្រូវនៅឡើយទេ រហូតមកទល់នឹងថ្ងៃនេះ។

[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3** ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ")។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឱ្យបកប្រែសេចក្តីសម្រេចនេះជាភាសាបារាំង ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

៦. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ពេលចេញសេចក្តីសម្រេច តាមសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលមានសមាសភាពចៅក្រមប្រាំពីររូប រួមទាំងចៅក្រម Agnieszka KLONOWIECKA-MILART[10]។

៧. នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានជ្រើសតាំងចៅក្រមបម្រុង Phillip RAPOZA ឱ្យជំនួសចៅក្រម Agnieszka KLONOWIECKA-MILART ដោយហេតុថាលោកស្រីចៅក្រមបានសុំលាឈប់ពីតំណែង (ដោយមិនបញ្ជាក់កាលបរិច្ឆេទ) និងដោយសារតែចាំបាច់ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ "ពីក្រុមប្រឹក្សាទាំងមូល និងចេញក្នុងពេលវេលាសមស្រប"[11]។ ដីកាជ្រើសតាំងចៅក្រមបម្រុងត្រូវបានជូនដំណឹង នៅវេលាម៉ោង ៣ និង ៦ នាទីរសៀល[12]។ ដូច្នេះ ទាល់តែចាប់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោង ៣ និង ៦ នាទី រសៀល តទៅទើបដីកានេះមានអានុភាព (ចៅក្រម Phillip RAPOZA មិនត្រូវបានតែងតែងជាផ្លូវការជាចៅក្រមពេញសិទ្ធិនោះទេ)[13]។

៨. នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ដោយដាក់បញ្ចូលឈ្មោះចៅក្រម Phillip RAPOZA ក្នុងសមាសភាពក្រុមប្រឹក្សាចៅក្រម នៅទំព័រមុខ។ សេចក្តីសម្រេចនេះត្រូវបានដាក់ចូលក្នុងសំណុំរឿង នៅម៉ោង ២ និង ៥៣ នាទី រសៀល[14] គឺ ១៣ នាទី **មុន**ពេលជូនដំណឹងអំពីដីកាជ្រើសតាំងចៅក្រមបម្រុង និង**មុន**ពេលតែងតាំងចៅក្រម Phillip RAPOZA រួចត្រូវបានជូនដំណឹង នៅម៉ោង ៣ និង ១៧ នាទី រសៀល។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលពិតជាបានធ្វើសេចក្តីសម្រេច **មុន**ដំណាក់កាលចុងក្រោយសម្រាប់ការបកប្រែ

---

[10] សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ទំព័រមុខ។

[11] ដីកាជ្រើសតាំងចៅក្រមបម្រុង ទំព័រ ៣។

[12] សូមមើលអ៊ីមែលជូនដំណឹង នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោង ៣ និង ៦ នាទី រសៀល។

[13] តាមភាពសមហេតុផល វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក កំណត់ថា ឯកសារទាំងអស់ (សំណើ សេចក្តីសម្រេច...) មានសុពលភាពចាប់ពីថ្ងៃជូនដំណឹងឯកសារទាំងនេះ។

[14] សូមមើលត្រានៅលើទំព័រមុខនៃសំណៅច្បាប់ដើមជាភាសាខ្មែរ (ម៉ោង ១៤ និង ៥២ នាទី) និងជាភាសាអង់គ្លេស (ម៉ោង ១៤ និង ៥៣ នាទី)។

និងកែសម្រួលសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅទៀត[15]។ អាស្រ័យហេតុនេះ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខត្រូវបានធ្វើឡើង **មុន**ពេលជ្រើសតាំងចៅក្រម Phillip RAPOZA ជាចៅក្រមពេញសិទ្ធិ។

៩. ដោយពុំមានព័ត៌មានអំពីកាលបរិច្ឆេទសុំលាឈប់របស់ចៅក្រម Agnieszka KLONOWIECKA-MILART កាលប្បវត្តិនេះនាំឱ្យលេចចេញនូវសេណារីយ៉ូពីរ ហើយសេណារីយ៉ូមួយណាក៏បង្ហាញអំពីភាពមិនត្រឹមត្រូវនៃសមាសភាពក្រុមប្រឹក្សាចៅក្រម ដែលបានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែរ៖ ១) ចៅក្រម Phillip RAPOZA មិនបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ឬ ២) ចៅក្រម Phillip RAPOZA បានចូលរួម ក្នុងឋានៈជាចៅក្រមបម្រុង។

១០. **សេណារីយ៉ូទី ១៖** ចៅក្រម Agnieszka KLONOWIECKA-MILART ទំនងជាបានចូលរួមធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ និងបានលាឈប់ មុនពេលចេញសេចក្តីសម្រេច ដោយនៅពេលនោះ សេចក្តីសម្រេចត្រូវបានធ្វើឡើង និងសរសេរ ជាពីរភាសា។ ចៅក្រម Phillip RAPOZA ទំនងជាមិនបានចូលរួមទេ ហើយសេចក្តីសម្រេចលើបណ្តឹងសាទុក្ខមិនគប្បីដាក់ឈ្មោះលោកទេ ដោយសារតែលោកមិនទាន់ត្រូវបានជ្រើសតាំងនៅឡើយ។

១១. **សេណារីយ៉ូទី ២៖** ប្រសិនបើចៅក្រម Agnieszka KLONOWIECKA-MILART ទំនងជាបានសុំលាឈប់ តាំងពីមុនថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ច្រើនថ្ងៃ ឬច្រើនសប្តាហ៍មកហើយ ចៅក្រម Phillip RAPOZA ទំនងជាបានចូលរួមធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ប៉ុន្តែ លោកមិនទាន់ត្រូវបានជ្រើសតាំងនៅឡើយទេ។

---

[15] ឧទាហរណ៍ សូមមើលសេចក្តីសម្រេច "លើបណ្តឹងសាទុក្ខភ្លាមរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់តាមវិធាន ៣៥" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ឯកសារ **E189/3/1/8** កថាខណ្ឌ ១០ ដោយអង្គជំនុំជម្រះតុលាការកំពូលពន្យល់ថា ខ្លួនមិនអាចពិចារណាលើសំណើសុំឱ្យទទួលយកភ័ស្តុតាងបន្ថែមដែលត្រូវបានជូនដំណឹង**មុនមួយសប្តាហ៍** មុនពេលចេញសេចក្តីសម្រេច បានទេ ដោយសារខ្លួនបានសម្រេចរួចហើយ ហើយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្ថិតក្នុងដំណាក់កាលចុងក្រោយសម្រាប់ធ្វើការបកប្រែ និងពិនិត្យកែសម្រួល។

១២. ផ្ទុយទៅវិញ យោងតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនានាត្រូវធ្វើឡើង និងចេញដោយក្រុមប្រឹក្សា**ទាំងមូល**នៃចៅក្រម**ពេញសិទ្ធិ**។

១៣. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិឲ្យធ្វើជាចៅក្រមជម្រះក្តី និងជ្រើសតាំងចៅក្រមបម្រុងឲ្យជំនួសចៅក្រមពេញសិទ្ធិដែលអវត្តមាន ឬមានធុរៈ[16]។ វិធានផ្ទៃក្នុងបញ្ជាក់ថា ក្នុងករណីចៅក្រមពេញសិទ្ធិណាម្នាក់អវត្តមាន ប្រធានអង្គជំនុំជម្រះ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមដទៃទៀត អាច "សម្រេចឲ្យលើកពេលសវនាការ ឬតែងតាំងចៅក្រមបម្រុងឲ្យជំនួសកន្លែងរបស់ចៅក្រមដែលអវត្តមានសម្រាប់កិច្ចបន្តនៃនីតិវិធី"[17]។ ចៅក្រមបម្រុង "មិនមានសិទ្ធិក្នុងការបញ្ចេញទស្សនៈ ឬសម្រេចអ្វីមួយឡើយ លើកលែងតែ និងរហូតដល់ពេលដែលត្រូវបានតែងតាំងឲ្យជំនួសចៅក្រមពេញសិទ្ធិណាម្នាក់"[18]។ ជំពូកទី ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក៖ "ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ" ចែងថា ប្រធានត្រូវធ្វើការកោះប្រជុំចៅក្រម "ដែលបានតែងតាំង" នៅក្នុងរយៈពេលសមស្រប ដើម្បីដំណើរការងារនៃអង្គជំនុំជម្រះវិសាមញ្ញ[19] ហើយប្រសិនបើមិនអាចរកបានសំឡេងជាឯកច្ឆន្ទបានទេ សេចក្តីសម្រេច "ត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើន និងមតិភាគតិច"[20]។

១៤. ក្នុងសេណារីយ៉ូទាំងពីរខាងលើ ពេលសេចក្តីសម្រេចលើបណ្តឹងសាទុក្ខត្រូវបានដាក់ចូលក្នុងសំណុំរឿង ក្រុមប្រឹក្សាចៅក្រមរបស់អង្គជំនុំជម្រះតុលាការកំពូលមានសមាសភាពចៅក្រមពេញសិទ្ធិតែ ៦ រូប ប៉ុណ្ណោះ ក្នុងចំណោមចៅក្រម ៧ រូប ដែលច្បាប់បានតម្រូវ[21]។ ទោះបីជាចៅក្រមបម្រុង Phillip RAPOZA មានវត្តមាន ឬអវត្តមាន ពេលអង្គជំនុំជម្រះបំពេញការងារដើម្បីឈានទៅធ្វើសេចក្តីសម្រេចនេះក៏ដោយ ក៏លោកមិនអាចបញ្ចេញមតិយោបល់ ឬចូលរួមសម្រេចបានឡើយ នៅ

---

[16] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ១១ ថ្មី។

[17] វិធាន ៧៩(៤) និង ១០៤ ស្ទួន នៃវិធានផ្ទៃក្នុង។

[18] វិធាន ៧៩(៣) នៃវិធានផ្ទៃក្នុង។

[19] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ១៥។

[20] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ១៤ ថ្មី។

[21] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ៩ ថ្មី វាក្យខណ្ឌ ២៖ តុលាការកំពូលមានសមាសភាព "ចៅក្រមប្រាំពីររូប"។

មុនពេលលោកត្រូវបានជ្រើសតាំងជាចៅក្រមពេញសិទ្ធិ ឱ្យជំនួសចៅក្រមលាឈប់ Agnieszka KLONOWIECKA-MILART ។

១៥. ដូច្នេះ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខត្រូវតែទុកជាមោឃៈ ដោយហេតុថាសេចក្តីសម្រេចនេះរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន ក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់។

## ផ្នែកទី ២. ការរំលោភលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់

១៦. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា អង្គជំនុំជម្រះត្រូវធានាថា ការជំនុំជម្រះក្តីប្រព្រឹត្តទៅ "បានត្រឹមត្រូវ និងឆាប់រហ័ស ទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ"។ អង្គជំនុំជម្រះអនុវត្តយុត្តាធិការរបស់ខ្លួន "សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"[22]។

១៧. យោងតាមមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។ បទប្បញ្ញត្តិនេះត្រូវបានដកស្រង់ចេញពីមាត្រា ១៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងត្រូវបានលើកយកមកធ្វើជាសំអាងជាច្រើន នៅក្នុងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។

[22] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី។

១៨. តុលាការសិទ្ធិមនុស្សអឺរ៉ុបរម្លឹកជារឿយៗថា "តុលាការ" ត្រូវតែ "បង្កើតឡើងដោយច្បាប់" ជានិច្ច ហើយពាក្យពេចន៍នេះឆ្លុះបញ្ចាំងអំពីគោលការណ៍នៃនីតិរដ្ឋ[23]។ "ច្បាប់" នេះ មិនមែនសំដៅត្រឹមតែច្បាប់ស្តីពីការបង្កើត និងសមត្ថកិច្ចរបស់អង្គតុលាការប៉ុណ្ណោះទេ ថែមទាំងបទប្បញ្ញត្តិផ្សេងៗទៀតនៃច្បាប់ជាតិទៀតផង ហើយការមិនគោរពបទប្បញ្ញត្តិទាំងនេះនាំឱ្យមានភាពមិនត្រឹមត្រូវដល់ការចូលរួមរបស់ចៅក្រមមួយ ឬច្រើនរូប ក្នុងការពិចារណាលើរឿងក្តី[24]។ ប្រយោគ "បង្កើតឡើងដោយច្បាប់" មិនពាក់ព័ន្ធត្រឹមតែមូលដ្ឋានច្បាប់នៃអត្ថិភាពរបស់ "តុលាការ" ប៉ុណ្ណោះទេ ថែមទាំងពាក់ព័ន្ធនឹងសមាសភាពចៅក្រមនៅក្នុងរឿងក្តីនីមួយៗ[25] និងការគោរពដោយតុលាការនូវវិធានជាក់លាក់ដែលគ្រប់គ្រងតុលាការនោះ ទៀតផង[26]។

១៩. ឧទាហរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា សិទ្ធិរបស់ម្ចាស់សំណើក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់ ត្រូវបានរំលោភបំពាន ដោយសារភាពល្មើសជាក់ស្តែងនឹង

---

[23] រឿងក្តី *Kontalexis ទល់នឹងប្រទេសក្រិច* (សំណើលេខ ៥៩០០០/០៨) សាលដីកា ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ("សាលដីកាលើរឿងក្តី *Kontalexis តទល់នឹងប្រទេសក្រិច*") កថាខណ្ឌ ៣៨, រឿងក្តី *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* (សំណើលេខ ៣០៣២៣/០២) សាលដីកា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ("សាលដីកាលើរឿងក្តី *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី*") កថាខណ្ឌ ១០៣, រឿងក្តី *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី* (សំណើលេខ ៤៣១៣/០៤) សាលដីកា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ("សាលដីកាលើរឿងក្តី *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី*") កថាខណ្ឌ ៦៧, រឿងក្តី *Lavents ទល់នឹងប្រទេសលេតតូនី* (សំណើលេខ ៥៨៤៤២/០០) សាលដីកា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ ("សាលដីកាលើរឿងក្តី *Lavents ទល់នឹងប្រទេសលេតតូនី*") កថាខណ្ឌ ១១៤។

[24] សាលដីកាលើរឿងក្តី *Kontalexis ទល់នឹងប្រទេសក្រិច* កថាខណ្ឌ ៣៨, សាលដីកាលើរឿងក្តី *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ១០៤, សាលដីកាលើរឿងក្តី *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ៦៨, សាលដីកាលើរឿងក្តី *Lavents ទល់នឹងប្រទេសលេតតូនី* កថាខណ្ឌ ១១៤។

[25] សាលដីកាលើរឿងក្តី *Kontalexis ទល់នឹងប្រទេសក្រិច* កថាខណ្ឌ ៤២, សាលដីកាលើរឿងក្តី *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ១០៤, សាលដីកាក្នុងរឿងក្តី *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ៦៨, រឿងក្តី *Posokhov ទល់នឹងប្រទេសរុស្ស៊ី* (សំណើលេខ ៦៣៤៨៦/០០) សាលដីកា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ៣៩, សាលដីកាលើរឿងក្តី *Lavents ទល់នឹងប្រទេសលេតតូនី* កថាខណ្ឌ ១១៤។

[26] សាលដីកាលើរឿងក្តី *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ១០៥, សាលដីកាលើរឿងក្តី *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី* កថាខណ្ឌ ៦៩, រឿងក្តី *Sokurenko និង Strygun ទល់នឹងប្រទេសអ៊ុយក្រែន* (សំណើលេខ ២៩៤៥៨/០៤ និង ២៩៤៦៥/០៤) សាលដីកា ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ២៤។

បទប្បញ្ញត្តិជាតិពាក់ព័ន្ធ ដែលតម្រូវឲ្យកំណត់ហេតុសវនាការចង្អុលបង្ហាញអំពីសំអាងហេតុនាំឲ្យចៅក្រមពេញសិទ្ធិមិនអាចមានវត្តមានបាន និងត្រូវជំនួសដោយចៅក្រមបម្រុងនៅថ្ងៃសវនាការ[27]។ លើសពីនេះទៅទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថា ការមិនផ្តល់ព័ត៌មានលម្អិតអំពីមូលហេតុនៃធុរៈ គ្រប់គ្រាន់ឲ្យបង្កជាមន្ទិលសង្ស័យចំពោះតម្លាភាពនៃនីតិវិធីជំនួស និងការពិតនៃសំអាងហេតុ[28]។

២០. ក្នុងករណីនេះ ការមិនគោរពបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាននៃផ្ទៃក្នុង ដែលតម្រូវឲ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើង និងចេញដោយក្រុមប្រឹក្សាពេញលេញនៃចៅក្រមពេញសិទ្ធិ ៧ រូប បានបណ្តាលឲ្យរំលោភលើសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់។

២១. ការរំលោភបំពាននេះបានបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់លោក ខៀវ សំផន ដែលត្រូវបានជំនុំជម្រះដោយតុលាការនៃអង្គការសហប្រជាជាតិ ដែលត្រូវបានសន្មតថាគោរពគោលការណ៍នៃនីតិរដ្ឋ និងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូល ដែលជាអ្នកសម្រេចចុងក្រោយដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះសាលាដំបូងវិញ[29] ត្រូវបានសន្មតថាជាអ្នកធានាជាចុងក្រោយឲ្យមានការគោរពនីតិវិធី និងសិទ្ធិរបស់លោក ខៀវ សំផន។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមិនអាចហ៊ានរំលោភបំពាននីតិវិធី និងសិទ្ធិ ដោយមិនបំផ្លាញធ្ងន់ធ្ងរដល់សេចក្តីទុកចិត្តរបស់ជនជាប់ចោទ (និងសាធារណជនជាតិ ក៏ដូចជាអន្តរជាតិ) លើធម្មានុរូបភាពរបស់តុលាការបានទេ។

២២. **<u>ជាសេចក្តីសន្និដ្ឋាន</u>** មេធាវីការពារក្តីគ្មានជម្រើសអ្វីផ្សេងក្រៅពីលើកឡើងនូវមោឃភាពនេះ ជាសាធារណៈ និងស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ដែលជាដើមហេតុ ឲ្យដោះស្រាយបញ្ហានេះ។ អង្គជំនុំជម្រះតុលាការកំពូលគ្មានជម្រើសអ្វីក្រៅពីធ្វើមោឃភាពសេចក្តីសម្រេច ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាចៅក្រមដែលមានសមាសភាពមិនត្រឹមត្រូវ និងចេញសេចក្តីសម្រេចថ្មីលើបណ្តឹង

[27] សាលដីកាលើរឿងក្តី *Kontalexis ទល់នឹងប្រទេសក្រិច* កថាខណ្ឌ ៤២-៤៤។

[28] សាលដីកាលើរឿងក្តី *Kontalexis ទល់នឹងប្រទេសក្រិច* កថាខណ្ឌ ៤៣។

[29] ច្បាប់ស្តីការបង្កើត អ.វ.ត.ក មាត្រា ៣៦ ថ្មី និងវិធាន ១០៤(៣) នៃវិធានផ្ទៃក្នុង។

សាទុក្ខ ដែលលើកនេះ គោរពនីតិវិធី និងសិទ្ធិរបស់លោក ខៀវ សំផន។ សេចក្ដីសម្រេចថ្មីដែលចេញដោយក្រុមប្រឹក្សាពេញលេញ ដែលមានសមាសភាពចៅក្រមពេញសិទ្ធិ ៧ រូប ពោលគឺដោយមានការចូលរួមពិតប្រាកដ និងត្រឹមត្រូវពីចៅក្រម Phillip RAPOZA ប្រហែលជាអាចបញ្ចៀសកំហុសជាក់ស្ដែងជាច្រើន ក្នុងសេចក្ដីសម្រេចដែលមិនអាចយកជាការបាន និងបញ្ចៀសការបំប្លែងកម្មវត្ថុនៃបណ្ដឹងសាទុក្ខ (ដែលមិនមែនផ្ដោតលើសេចក្ដីសង្ខេបសាលក្រមនោះទេ គឺផ្ដោតលើផ្នែកសម្រេចសេចក្ដីនៃសាលក្រម)។

២៣. **អាស្រ័យហេតុនេះ** មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា **ធ្វើមោឃភាព** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ និង**ចេញ**សេចក្ដីសម្រេចថ្មី ដោយគោរពនីតិវិធី និងសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |